# ស្ថាប័នប្រឆាំងអំពើពុករលួយ

រៀបចំ និងផ្សព្វផ្សាយដោយអង្គភាពប្រឆាំងអំពើពុករលួយ

# មាតិកា

I. ប្រវត្តិ

II. ស្ថាប័នប្រឆាំងអំពើពុករលួយ

III. បេសកកម្ម

IV. អំណាចស៊ើបអង្កេត

V. បទល្មើសពុករលួយ

VI. របៀបដាក់ពាក្យប្តឹង

VII. សំណួរ-ចម្លើយ

# I. ប្រវត្តិ

- រាជរដ្ឋាភិបាលកម្ពុជា តែងតែយកចិត្តទុកដាក់លើការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ថ្ងៃទី ២៧ ខែតុលា ឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាល បានបង្កើត**អង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ**
- ថ្ងៃទី២២ ខែសីហា ឆ្នាំ ២០០៦ រាជរដ្ឋាភិបាល បានកែសម្រួលរចនា សម្ព័ន្ធអង្គភាពនេះឡើងវិញ ដោយប្តូរឈ្មោះថា **អង្គភាពប្រឆាំងអំពើពុករលួយ** ស្ថិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រី
- ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវបានបង្កើតដោយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

# II. រចនាសម្ព័ន្ធរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- **កសាងយុទ្ធសាស្ត្រ** និង**នយោបាយ**ប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ពិគ្រោះយោបល់ និងផ្តល់អនុសាសន៍ដល់អង្គភាពប្រឆាំងអំពើពុករលួយពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- រៀបចំកសាង**ផែនការសកម្មភាព**ប្រយុទ្ធប្រឆាំងអំពើពុករលួយស្របតាមយុទ្ធសាស្ត្រ និងនយោបាយរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
- ដឹកនាំការងារទប់ស្កាត់ និងបង្ក្រាបអំពើពុករលួយ។

# ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- ឃ្លាំមើលដំណើរការការងារនៃអង្គភាពប្រឆាំងអំពើពុករលួយ។

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- អនុវត្តច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងបទល្មើសពុករលួយ
- តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និងធ្វើការសិក្សាស្រាវជ្រាវព្រមទាំងលើកវិធានការនានាពាក់ព័ន្ធនឹងបទល្មើសពុករលួយនៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈ និងឯកជនទាំងអស់ស្របតាមនីតិវិធីជាធរមាន
- ទទួល និងពិនិត្យរាល់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងអំពើពុករលួយព្រមទាំងចាត់ការទៅតាមនីតិវិធីជាធរមាន។

# ស្ថាប័នប្រឆាំងអំពើពុករលួយ

| ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ | អង្គភាពប្រឆាំងអំពើពុករលួយ |
|---|---|
| **ភារកិច្ច** | **ភារកិច្ច** |
| - ស្នើអង្គភាពប្រឆាំងអំពើពុករលួយឱ្យរាយការណ៍ ឬបំភ្លឺ។ | • ទទួលឆ្លើយបំភ្លឺ ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរចំពោះរាល់សំណួរដែលលើកឡើងដោយសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ឬសមាជិករដ្ឋសភា។ |

# ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- ធ្វើរបាយការណ៍ជូននាយករដ្ឋមន្ត្រី អំពីដំណើរការរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូននាយករដ្ឋមន្ត្រី
- រៀបចំ និងអនុម័តបទបញ្ជាផ្ទៃក្នុង ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- ធ្វើរបាយការណ៍អំពីសកម្មភាពទាំងឡាយរបស់អង្គភាពប្រឆាំងអំពើពុករលួយ ជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
- ពិនិត្យ និងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងរបស់អង្គភាពប្រឆាំងអំពើពុករលួយ
- បម្រើសេវាការងារជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ
- បំពេញភារកិច្ចផ្សេងៗទៀតតាមបញ្ញត្តរបស់ច្បាប់ជាធរមាន និងតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

# រចនាសម្ព័ន្ធរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ



## III.បេសកកម្ម

- ប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ការស៊ើបអង្កេតបទល្មើសពុករលួយជាសមត្ថកិច្ចផ្តាច់មុខរបស់ អ.ប.ព.
- អនុវត្តវិធានការណ៍ចំនួន ៣ ធំៗ៖
  - អប់រំ
  - បង្ការទប់ស្កាត់
  - អនុវត្តច្បាប់ ។

# IV.អំណាចស៊ើបអង្កេតរបស់អង្គភាពប្រឆាំងអំពើពុករលួយ

ដោយបដិប្បញ្ញត្តិទៅនឹងមាត្រា១០៥(ការហាមឃាត់មិនឱ្យស្ដាប់ដោយឯកឯងជាអាទិ៍) និង មាត្រា ១៧២(ការស្ដាប់ទូរស័ព្ទជាអាទិ៍ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលមានតម្រុយជាក់លាក់ថាមានបទល្មើសពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយអាច ៖

ក- ពិនិត្យនិងដាក់ឱ្យស្ថិតក្រោមការឃ្លាំមើលនូវគណនីធនាគារឬគណនីឯទៀតដែលចាត់ទុក ដូចជាគណនីធនាគារ។

ខ- ធ្វើការត្រួតពិនិត្យនិងបង្គាប់ឱ្យផ្ដល់ឬថតចម្លងលិខិតយថាភូត ឬលិខិតឯកជន ឬឯកសារធនាគារ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មទាំងអស់។

គ- តាមដាន ឃ្លាំមើល លបស្ដាប់ លបថតសំឡេងនិងរូបភាព និងដាក់ខ្សែទូរស័ព្ទក្រោម ការលបស្ដាប់និងថត។

ឃ- ចូលទៅពិនិត្យឯកសារនានាព្រមទាំងឯកសាររក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក។

ង- រៀបចំប្រតិបត្តិការដែលមានគោលដៅប្រមូលភស្តុតាងជាក់ស្ដែង។

វិធានការខាងលើនេះមិនត្រូវចាត់ទុកថាជាការរំលោភលើការសម្ងាត់វិជ្ជាជីវៈឡើយ។ ការសម្ងាត់របស់ធនាគារក៏មិនមែនជាយុត្តិកម្ម សម្រាប់បដិសេធមិនផ្ដល់ភស្តុតាងពាក់ព័ន្ធនឹងបទល្មើសពុករលួយ ដែលមានបញ្ញត្តនៅក្នុងច្បាប់នេះឡើយ។

# V. ប្រភេទនៃបទល្មើសពុករលួយ

## ធាតុផ្សំនៃបទល្មើស

- ធាតុសត្យានុម័ត
- ធាតុអត្តនោម័ត
- ធាតុនីត្យានុកូល

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ១-បទស៊ីសំណូក<br>ម.៥៩៤ ក្រ.ព្រ.ទ | -មន្ត្រីរាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត | -ទទូចសុំ ឬយល់ព្រមដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោល ទទួលអំណោយជំនូន ការសន្យា ឬ អត្ថប្រ-យោជន៍ណាមួយ<br>-បំពេញ ឬមិនបំពេញកិច្ច នៃមុខងារ ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន | -ពន្ធនាគារពី ៧ឆ្នាំ ទៅ១៥ឆ្នាំ |
| ២-បទសូកប៉ាន់<br>ម.៦០៥ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់អំណោយ ឬជំនូន ធ្វើការសន្យាជាមួយ ឬផ្តល់ អត្ថប្រយោជន៍ អ្វីមួយ<br>-បំពេញ ឬមិនបំពេញកិច្ច នៃមុខងារ ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន | -ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម និងទោស |
|---|---|---|---|
| ៣-បទស៊ីសំណូកនៃនិយោជិត ម.២៧៨ ក្រ.ព្រ.ទ | -និយោជិត | - មានការទទួចសុំ ឬយល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ ដើម្បីបំពេញ ឬមិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង និងដោយគ្មានការព្រមព្រៀង | - ពន្ធនាគារ ៦ខែ ទៅ២ឆ្នាំ<br>- ពិន័យពី ១លានរៀលទៅ ៤លានរៀល |
| ៤-បទសូកប៉ាន់ដល់និយោជិត ម.២៧៩ ក្រ.ព្រ.ទ | - គ្រប់បុគ្គល | -មានការប្រគល់...ឲ្យនិយោជិត ដោយនិយោជកមិនបានដឹង និង គ្មានការព្រមព្រៀង | |
| ៥-បទស៊ីសំណូករបស់អភិបាលជាអាទិ៍ ម.២៨០ ក្រ.ព្រ.ទ | -អភិបាល ឬបុគ្គលផ្សេងទៀតដូចមានចែងក្នុងមាត្រា៣៩៣ នៃក្រមព្រហ្មទណ្ឌ | -បានទទួលផលប្រយោជន៍ជាទ្រព្យសម្បត្តិ ឬបានទាមទារ ឬបានសន្យាទទួលផលប្រយោជន៍ ដោយបានទទួលការពឹងពាក់ខុសច្បាប់ | -ពន្ធនាគារ ៥ឆ្នាំ ទៅ១០ឆ្នាំ |
| | -គ្រប់បុគ្គល | បានផ្ដល់ផលប្រយោជន៍ ឬបានស្នើសុំផ្ដល់ ឬសន្យាផ្ដល់ ផល-ប្រយោជន៍ | |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម និងទោស |
|---|---|---|---|
| ៦-បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម<br>ម.៥១៧ ក្រ.ព្រ.ទ | -ចៅក្រមអាសនៈ ឬ ចៅក្រមអយ្យការ | -ទទួចសុំ ឬយល់ព្រមដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលទទួលអំណោយ ជំនូនការសន្យា ឬអត្ថប្រយោជន៍ណាមួយ<br>-បំពេញ ឬមិនបំពេញកិច្ចនៅក្នុងមុខងារ | - ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ |
| ៧-បទសូកប៉ាន់ចំពោះចៅក្រម<br>ម.៥១៨ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់ជូនចៅក្រមនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ<br>-បំពេញ ឬមិនបំពេញកិច្ចជាមុខងារ | - ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ៨-បទស៊ីសំណូករបស់សាក្សីដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ ម.៥៤៧ ក្រ.ព្រ.ទ | -សាក្សី | -ទទួចសុំ ឬយល់ព្រម ទទួលយកដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ<br>-មិនធ្វើសាក្សី ឬផ្តល់សក្ខីកម្មភូតកុហក | ពន្ធនាគារពី ៥ឆ្នាំទៅ១០ឆ្នាំ |
| ៩-បទសូកប៉ាន់សាក្សី ម.៥៤៨ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់ឲ្យសាក្សីដោយផ្ទាល់ ឬដោយប្រយោលនូវ អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍<br>-មិនធ្វើសាក្សី ឬផ្តល់សក្ខីកម្មភូតកុហក។ | |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ១០-បទស៊ីសំណូករបស់អ្នកបកប្រែ<br>ម.៥៥៣ ក្រ.ព្រ.ទ | -អ្នកបកប្រែ | -ទទូចសុំ ឬយល់ព្រមទទួល ដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រ-យោជន៍អ្វីមួយ<br>-ក្លែងខ្លឹមសារនៃភាសា ឬឯកសារដែលបកប្រែ | ពន្ធនាគារ ៥ឆ្នាំ ទៅ១០ឆ្នាំ |
| ១១-បទសូកប៉ាន់អ្នកបកប្រែ<br>ម.៥៥៤ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់ឲ្យអ្នកបកប្រែដោយផ្ទាល់ ឬដោយប្រយោល នូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍<br>-ក្លែងខ្លឹមសារនៃភាសា ឬឯកសារបកប្រែ។ | |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **១២-បទស៊ីសំណូករបស់អ្នកជំនាញ**<br>ម.៥៥៥ ក្រ.ព្រ.ទ | - អ្នកជំនាញ | -ទទួចសុំ ឬយល់ព្រមដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រ-យោល ទទួល អំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយ<br>-ក្លែងនៅក្នុងរបាយការណ៍ ជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍ដោយ ផ្ទាល់មាត់របស់ខ្លួននូវទិន្នន័យ ឬ លទ្ធផលកោសល្យវិច័យ | ពន្ធនាគារ ៥ឆ្នាំ ទៅ ១០ឆ្នាំ |
| **១៣-បទសូកប៉ាន់អ្នកជំនាញ**<br>ម.៥៥៦ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់ឲ្យអ្នកជំនាញដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន កាសន្យា<br>-ក្លែងក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍ ដោយផ្ទាល់មាត់របស់ខ្លួននូវទិន្នន័យ ឬលទ្ធផលកោសល្យវិច័យ | |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ១៤-បទស៊ីសំណូកដោយអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត ម.៦៣៧ ក្រ.ព្រ.ទ | -បុគ្គលក្នុងការប្រកបវិជ្ជាជីវៈ | -ទទូចសុំ ឬយល់ព្រមទទួលយកដោយផ្ទាល់ ឬដោយប្រយោលនូវ អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ<br>-ធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពី ការណ៍ភាព ដែលតាមជាក់ស្តែងមិនមែនការពិត | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |
| ១៥-បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត ម.៦៣៨ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់អំណោយ ជំនូន ការសន្យាជាមួយ ឬផ្តល់អត្ថប្រយោជន៍អ្វីមួយ<br>-ធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណ៍ភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត | -ពន្ធនាគារពី ១ឆ្នាំ ទៅ៣ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ៦លានរៀល |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ១៦-បទស៊ីសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈ ខាងវេជ្ជសាស្ត្រ ដើម្បីធ្វើ លិខិតបញ្ជាក់មិនពិត ម.៦៣៩ ក្រ.ព្រ.ទ | -គ្រូពេទ្យ ឬបុគ្គលដែលជាសមាជិកនៃ គណៈវិជ្ជាជីវៈវេជ្ជសាស្ត្រ | -ទទួលសុំ ឬយល់ព្រមទទួល ដោយផ្ទាល់ ឬដោយប្រយោល នូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |
| ១៧-បទសូកប៉ាន់ចំពោះសមាជិកនៃគណៈ វិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត ម.៦៤០ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់អំណោយ ជំនូន ការសន្យាជាមួយ ឬផ្តល់អត្ថប្រ-យោជន៍ អ្វីមួយដល់គ្រូពេទ្យ ឬបុគ្គលដែលជាសមាជិក នៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណភាព ដែល តាមជាក់ស្តែងមិនមែនជាការពិត | -ពន្ធនាគារពី ១ឆ្នាំ ទៅ៣ឆ្នាំ<br>-ពិន័យពី ២លានរៀលទៅ ៦លានរៀល |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ១៨-បទស៊ីសំណូកនៃមន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសា-ធារណៈ<br>ម. ៣៣ ច្បាប់.ប.ព | -មន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ | -សុំទាមទារ ឬយល់ព្រម ទទួលដោយគ្មានសិទ្ធិ ដោយផ្ទាល់ ឬដោយប្រយោលនូវ អំណោយ ជំនូន ការសន្យា ឬអត្ថ-ប្រយោជន៍ណាមួយ | -ពន្ធនាគារពី ៧ឆ្នាំ ទៅ១៥ឆ្នាំ |
| ១៩-បទសូកប៉ាន់ចំពោះមន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ<br>ម. ៣៤ ច្បាប់.ប.ព | -គ្រប់បុគ្គល | -ប្រគល់អំណោយ ជំនូន ឬធ្វើការសន្យាជាមួយ ឬផ្ដល់អត្ថប្រយោជន៍ដល់មន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការ អន្តរជាតិសាធារណៈ | -ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ |

ស្ថាប័នប្រឆាំងអំពើពុករលួយ
#54 មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី III ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ (855) 23 219 223
www.acu.gov.kh

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **២០-បទដេញថ្លៃមិនត្រឹមត្រូវ**<br>ម.៣៨៧ ក្រ.ព្រ.ទ | -អ្នកចូលរួមដេញថ្លៃ<br>-គ្រប់បុគ្គលដែលពាក់ព័ន្ធ | -កម្ចាត់អ្នកដេញថ្លៃ ឬធ្វើឲ្យខូចការដេញថ្លៃដោយអំណោយ ការសន្យា ការព្រមព្រៀង ឬតាមមធ្យោបាយទុច្ចរិតដទៃទៀត | -ពន្ធនាគារពី ៦ខែ ទៅ២ឆ្នាំ<br>-ពិន័យពី ១លានរៀលទៅ ៤លានរៀល |
| **២១-និយមន័យនៃការសំអាតប្រាក់**<br>ម.៤០៤ ក្រ.ព្រ.ទ | -អ្នកមានសកម្មភាពវិជ្ជាជីវៈ<br>-ក្រុមមានការចាត់តាំង<br>-គ្រប់បុគ្គលដែលពាក់ព័ន្ធ | -យុត្តិកម្មកុហក ដើម្បីលាក់បំបាំងអត្ថប្រយោជន៍ផ្ទាល់ ឬប្រយោលនៃបទ ឧក្រិដ្ឋ ឬបទមជ្ឈិម។ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀល រហូតស្មើនឹងតម្លៃមូលនិធិ ឬតម្លៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសំអាតប្រាក់។ |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ២២-និយមន័យនៃវិតិក្រម ម.៥៩២-៥៩៣ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត | -ទាមទារ ឬទទួល ជាសិទ្ធជាពន្ធ ជាអាករ នូវចំនួនប្រាក់ដែលខ្លួនបានដឹងថាមិនត្រូវបង់ ឬដែលលើសពីចំនួនដែលគេត្រូវបង់<br>-យល់ព្រមក្រោមរូបភាពណាមួយ និងដោយមូលហេតុណាមួយក៏ដោយធ្វើការលើកលែង ឬការលោះលាចំពោះការបង់ពន្ធ ឬ អាករដែលខ្លួនដឹងថាខុសច្បាប់។ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ២៣-និយមន័យនៃជំនួញឥទ្ធិពលអកម្ម ម.៥៩៥-៥៩៦ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត | -ទទួចសុំ ឬយល់ព្រមទទួលដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយ ដើម្បីទទួលបានពីស្ថាប័នរដ្ឋដោយសារឥទ្ធិពលពិតប្រាកដ ឬដោយសន្មតនូវការងារលទ្ធកម្មសាធារណៈ គ្រឿងសម្គាល់កិត្តិយស ឬសេចក្តីសម្រេចអនុគ្រោះផ្សេងៗ ដទៃទៀត។ | -ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **២៤-បទជំនួញឥទ្ធិពលសកម្ម**<br>ម.៦០៦ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ដែលអោយដោយខុសច្បាប់នូវអត្ថប្រយោជន៍ដល់អ្នកដទៃ នៅក្នុងឱកាសនៃការធ្វើលទ្ធកម្មសាធារណៈ គ្រឿងសំគាល់កិត្តិយស ឬសេចក្តីសម្រេចអនុគ្រោះផ្សេងៗ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ |
| **២៥-និយមន័យនៃបក្ខានុគ្រោះ**<br>ម.៥៩៩-៦០០ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត | -ដែលអោយដោយខុសច្បាប់នូវអត្ថប្រយោជន៍ដល់អ្នកដទៃ នៅក្នុងឱកាសនៃការធ្វើលទ្ធកម្មសាធារណៈ | -ពន្ធនាគារពី ៦ខែ ទៅ២ឆ្នាំ<br>-ពិន័យជាប្រាក់ ១លានរៀល ទៅ ៤លានរៀល |

# III. ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **២៦-និយមន័យនៃការកេងយកផលប្រយោជន៍ដោយខុសច្បាប់** ម.៥៩៧-៥៩៨ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសា-ធារណៈដោយការបោះឆ្នោត | -យកទទួល ឬរក្សាទុក ដោយផ្ទាល់ ឬដោយប្រយោលនូវផលប្រយោជន៍នៅក្នុងសហគ្រាសណាមួយដែល អ្នករាជការ ឬពលរដ្ឋនោះរ៉ាប់រង.. | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |
| **២៧-បទបំផ្លាញដោយចេត-នា និងគែបំបាត់ដោយទុច្ចរិត** ម.៦០១ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសា-ធារណៈដោយការបោះឆ្នោត | -គ្រប់គ្រងលិខិត បណ្ណមូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងទៀត ដោយសារមុខងារ បំផ្លាញចោលដោយចេតនា | -ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ ប្រសិនបើមានចេតនា |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **២៨-បទសម្លុតគំរាម** ម.៦០៧ ក្រ.ព្រ.ទ | -ជនណាមួយ | -ប្រើអំពើសម្លុតគំរាមដែលអនុវត្តទៅលើអ្នករាជការ ដើម្បីឲ្យបំពេញកិច្ច ឬមិនឲ្យបំពេញកិច្ចរបស់ខ្លួន ដើម្បីនឹងទទួលបានពីរាជការនូវសេចក្ដីសម្រេចអនុគ្រោះផ្សេងៗ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |
| **២៩-បទបំផ្លាញនិងគៃបំបាត់** ម.៦០៨ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -អំពើបំផ្លាញ គៃបំបាត់ ឬដកយកលិខិត បណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងទៀត ដែលរក្សាទុកដោយអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលណត្តិសាធារណៈដោយការបោះឆ្នោត | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **៣០-បទរំលោភអំណាច**<br>ម. ៣៥ ច្បាប់.ប.ព | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសា-ធារណៈដោយការបោះឆ្នោត | -ចាត់វិធានការរារាំងការអនុវត្តច្បាប់ដើម្បីទទួលបានដោយខុសច្បាប់ នូវអត្ថប្រ-យោជន៍ណាមួយក្នុងការបំពេញមុខងារ ឬឱកាស នៃការបំពេញមុខងារ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យពី ៤លានរៀល ទៅ ១០លានរៀល<br>- ប្រសិនបើបទល្មើសមានប្រសិទ្ធភាព ទោសពន្ធនាគារដែលត្រូវប្រកាសគឺពី៥ឆ្នាំ ទៅ១០ឆ្នាំ។ |
| **៣១-បទមានទ្រព្យសម្បត្តិដោយខុសច្បាប់**<br>ម. ៣៦ ច្បាប់.ប.ព | -ជនណាដែលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិនិងបំណុល<br>(មាត្រា ១៧,១៩ នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ) | -ជាកំណើនទ្រព្យសម្បត្តិដែលមិនអាចផ្ដល់ការពន្យល់សមហេតុផលនូវការកើនឡើងនៃទ្រព្យសម្បត្តិនេះដោយប្រៀបធៀបទៅនឹងចំណូលស្របច្បាប់របស់ខ្លួន | -អាស្រ័យតាមប្រភេទនៃបទល្មើល។ |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ៣២-បទទទួលផលបន្តពីបទល្មើសពុករលួយ<br>ម. ៣៧ ច្បាប់.ប.ព | -គ្រប់បុគ្គល | -លាក់បំបាំង រក្សាទុក ឬ ជញ្ជូនរបស់អ្វីមួយដោយដឹងថារបស់នោះបានមកពីបទល្មើសពុករលួយ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល<br>(ក្នុងករណីមានស្ថានទម្ងន់ទោស ពន្ធនាគារ ពី ៥ឆ្នាំទៅ ១០ឆ្នាំ) |
| ៣៣-បទមិនប្រកាសទ្រព្យសម្បត្តិ និងបំណុល<br>ម. ៣៨ ច្បាប់.ប.ព | -ជនណាដែលមានចែងនៅក្នុង មាត្រា១៧ មាត្រា ១៨ និងមាត្រា១៩ នៃច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ | -មិនបានប្រកាសទ្រព្យសម្បត្តិ និងបំណុល ឬ<br>-ប្រកាសមិនត្រឹមត្រូវនូវទ្រព្យសម្បត្តិរបស់ខ្លួន។ | -ពន្ធនាគារពី១ខែ ទៅ១ឆ្នាំ និងពិន័យពី ១សែនរៀល ទៅ ២លានរៀល។<br>- ក្នុងករណីរឹងរូស មិនព្រមប្រកាសទ្រព្យសម្បត្តិ ទោសដែលត្រូវប្រកាសគឺទ្វេដង។ |

ស្ថាប័នប្រឆាំងអំពើពុករលួយ
#54 មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី III ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ (855) 23 219 223
www.acu.gov.kh

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ៣៤-បទទម្លាយការសម្ងាត់នៃប្រភពព័ត៌មានស្ដីពីអំពីពុករលួយ<br>ម. ៣៩ ច្បាប់.ប.ព | -ជនណាមួយ | -ធ្លាយការសម្ងាត់នៃប្រភពព័ត៌មានស្ដីពីអំពើពុករលួយ | -ពន្ធនាគារពី ១ឆ្នាំ ទៅ៥ឆ្នាំ |
| ៣៥-បទរារាំង និងជ្រៀតជ្រែកដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ<br>ម. ៤០ ច្បាប់.ប.ព | -អ្នករាជការសាធារណៈ យោធិន នគរបាលជាតិ ពលរដ្ឋ ដែលទទួលអាណត្តិតាមការបោះឆ្នោត មន្ត្រីសង្គមស៊ីវិល មន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ | -សម្លុតគំរាមកំហែង រារាំង ឬជ្រៀតជ្រែកក្នុងការបំពេញមុខងាររបស់មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ | -ពន្ធនាគារពី២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យពី ៤លានរៀល ទៅ ១០លានរៀល។ |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ៣៦-បទបរិហារ ដោយភូតកុហក<br>ម. ៤១ ច្បាប់.ប.ព | -គ្រប់បុគ្គល | -ប្ដឹងបរិហារដោយភូតកុហកដល់អង្គភាពប្រឆាំងអំពើពុករលួយ ឬតុលាការនូវអង្គហេតុបទល្មើសពុករលួយ ដែលនាំទៅដល់ការស្រាវជ្រាវឥតប្រយោជន៍ | -ពន្ធនាគារពី ១ខែ ទៅ៦ខែ<br>-ពិន័យជាប្រាក់ពី ១សែនរៀល ទៅ១លានរៀល |
| ៣៧-បទបំពានលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក<br>ម. ៤២ ច្បាប់.ប.ព | -គ្រប់បុគ្គលទាំងឡាយណាដែលគ្មានសិទ្ធិ | -ផ្ទេរ ធ្វើអនុប្បទាន ឬធ្វើការដោះដូរនូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក ។ | -ពន្ធនាគារពី១ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យពី ២លានរៀល ទៅ ១០លានរៀល។ |

# ប្រភេទនៃបទល្មើសពុករលួយ

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ៣៨-បទល្មើសពុករលួយតូចតាច និងទោស ម. ៤៣ ច្បាប់.ប.ព | -ជនណាមួយ | -ប្រព្រឹត្តឡើងសម្រាប់ជីវភាពប្រចាំថ្ងៃ ដែលមានលក្ខណៈតូចតាច មិនបង្កព្យសនកម្មធ្ងន់ធ្ងរ ដល់សង្គម<br>-មានការវាយតម្លៃទទួលស្គាល់ពី អង្គភាពប្រឆាំងអំពើពុករលួយ ថាជាបទល្មើសតូចតាច | -ពន្ធនាគារពី ៧ថ្ងៃ ទៅ៥ឆ្នាំ |

**សម្គាល់៖ បទល្មើសពុករលួយមាន ៣៨ បទល្មើស ក្នុងនោះមាន៖**

**-ប្រភេទស៊ីសំណូក មាន ១០ បទល្មើស**

**- ប្រភេទសូកប៉ាន់ មាន ៩ បទល្មើស**

**- ប្រភេទបទល្មើសផ្សេងៗទៀត មាន ១៩ បទល្មើស ។**

## VI. របៀបដាក់ប្តឹង

-ប្តឹងផ្ទាល់នៅ អ.ប.ព. អាគារលេខ៥៤ មហាវិថីព្រះនរោត្តម ភ្នំពេញ

-សរសេរពាក្យប្តឹងរួចដាក់ក្នុងប្រអប់ស តាមបណ្តោយមហាវិថីព្រះមុនីវង្ស

-ផ្ញើពាក្យប្តឹងតាមប្រៃសណីយ៍ដែលនៅជិតលំនៅដ្ឋានរបស់លោកអ្នក

-អ៊ីម៉ែលពាក្យប្តឹង : complaint@acu.gov.kh

-លេខទូរស័ព្ទពិសេស : 1282 (មិនគិតថ្លៃ)

-លេខទូរស័ព្ទ : 023221653

--គេហទំព័រ អ.ប.ព : www.acu.gov.kh

# សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!

# VII. សំណួរ-ចម្លើយ

# ស្ថាប័នប្រឆាំងអំពើពុករលួយ

*រៀបចំ និងធ្វើបទបង្ហាញដោយអង្គភាពប្រឆាំងអំពើពុករលួយ*

# មាតិកា


I. ប្រវត្តិ

II. វាក្យស័ព្ទ និង សញ្ញាណនៃអំពើពុករលួយ

III. ស្ថាប័នប្រឆាំងអំពើពុករលួយ

ក-ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

ខ-អង្គភាពប្រឆាំងអំពើពុករលួយ

IV. បទល្មើសពុករលួយ

V. សំណួរ-ចម្លើយ

# I. ប្រវត្តិ

- រាជរដ្ឋាភិបាលកម្ពុជា តែងតែយកចិត្តទុកដាក់លើការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាល បានបង្កើត**អង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ**
- ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៦ រាជរដ្ឋាភិបាល បានកែសម្រួលរចនា សម្ព័ន្ធអង្គភាពនេះឡើងវិញ ដោយប្តូរឈ្មោះថា **អង្គភាពប្រឆាំងអំពើពុករលួយ** ស្ថិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រី
- ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១០ ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវបានបង្កើតដោយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។
- ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១១ ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវបានប្រកាសឲ្យប្រើ។

# I. ប្រវត្តិ

- ការប្រឆាំងអំពើពុករលួយ ជាការងារអាទិភាពបំផុត និងក្តៅគគុករបស់រាជរដ្ឋាភិបាល នៅក្នុងអាណត្តិ ទី ៥ នេះ ក៏ដូចជាអណត្តិបន្តបន្ទាប់ទៀត ដោយប្រកាន់យកវិធានការណ៍ប្រទាក់ក្រឡាគ្នាចំនួន បី ៖
  - ការអប់រំ បង្ការទប់ស្កាត់
  - ការអនុវត្តច្បាប់ បង្ក្រាបបទល្មើសពុករលួយ
  - ការចូលរួមគាំទ្រពីមហាជន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

# II- វាក្យស័ព្ទ និង សញ្ញាណនៃអំពើពុករលួយ

## ក- វាក្យស័ព្ទ

1. **បទល្មើសពុករលួយ** មានន័យថា បទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុង ជំពូកទី៦ នៃច្បាប់នេះ។

2. **អ្នករាជការសាធារណៈ** មានន័យថា ៖

ក/ បុគ្គលដែលបម្រើការងារនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការ ដែលត្រូវបានតែងតាំងដោយលិខិតបទដ្ឋានគតិយុត្ត ទោះជាអចិន្ត្រៃយ៍ឬជាបណ្ដោះអាសន្នក្ដី ទោះជាបាន ឬមិនបានទទួលប្រាក់ឈ្នួលក្ដី ដោយមិនគិតពីឋានៈ អាយុរបស់ បុគ្គលនោះឡើយ។

ខ/ បុគ្គលឯទៀតដែលធ្វើការក្នុងមុខងារសាធារណៈ រួមទាំងទីភ្នាក់ងារសារធារណៈ ឬសហគ្រាសសាធារណៈ ព្រមទាំងស្ថាប័នសាធារណៈដទៃទៀត ដែលមានចែងនៅក្នុងច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា។

# II-វាក្យស័ព្ទ

3. **មន្ត្រីសាធារណៈបរទេស** មានន័យថាមន្ត្រីបរទេសដែលកាន់តំណែងក្នុងស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ឬស្ថាប័នតុលាការរបស់ប្រទេសក្រៅ ទោះជាបានតែងតាំង ឬបោះឆ្នោតជ្រើសរើសក៏ដោយ និងជនបរទេសដែលអនុវត្តមុខងារសាធារណៈសម្រាប់ប្រទេសក្រៅណាមួយ រួម មានទីភ្នាក់ងារសាធារណៈ ឬសហគ្រាសសាធារណៈ។
4. **មន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ** មានន័យថា មន្ត្រីអន្តរជាតិ ឬជនណាដែលទទួលបានការអនុញ្ញាតពីអង្គការអន្តរជាតិឲ្យបំពេញភារកិច្ចក្នុងនាមអង្គការអន្តរជាតិនោះ។
5. **ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត** មានន័យថា សមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋទទួលអាណត្តិដោយការបោះឆ្នោតដើម្បីបំពេញមុខងារសាធារណៈដទៃទៀត។

6. **ចៅក្រម** មានន័យថាចៅក្រមអាសនៈ និងចៅក្រមអយ្យការ។

7. **នីតិបុគ្គល** មានន័យថាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។

8. **សង្គមស៊ីវិល** មានន័យថាសហគមន៍ ឬក្រុមមនុស្សដែលបង្កើតឡើង ដើម្បីធ្វើសកម្មភាពក្នុងការការពារផលប្រយោជន៍លើវិស័យសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ វិទ្យាសាស្ត្រ វប្បធម៌ និងសាសនា មានជាអាទិ៍ សមាគម អង្គការក្រៅរដ្ឋាភិបាល គណបក្សនយោបាយ។

9. **អត្ថប្រយោជន៍** មានន័យថា ៖

ក/ អំណោយអ្វីមួយ កម្ចី តម្លៃឈ្នួល រង្វាន់ ឬកម្រៃជើងសារដែលមិនមានការអនុញ្ញាត ដោយច្បាប់ជាធរមាន ជាទឹកប្រាក់ ឬជាវត្ថុមានតម្លៃ ឬជាទ្រព្យសម្បត្តិប្រភេទអ្វីមួយ។

ខ/ ការងារ តំណែង មុខងារ កិច្ចព្រមព្រៀង ឬកិច្ចសន្យាអ្វីមួយ។

គ/ ការបង់ប្រាក់ ការលើកលែង ការលុបចោល ការលុបបំបាត់នូវប្រាក់កម្ចីអ្វីមួយ កាតព្វកិច្ច ឬបំណុលដទៃទៀតទោះជាទាំងមូលក្តី ឬដោយផ្នែកក្តី។

ឃ/ សេវាកម្មឯទៀត ឬការផ្តល់ជាគុណប្រយោជន៍ រួមទាំងកិច្ចការពារមិនឲ្យមានការដាក់ទណ្ឌកម្ម ដែលលេចចេញពីអំពើ ឬដំណើរការនៃការដាក់ទណ្ឌកម្មរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ទោះបីទណ្ឌកម្មនេះត្រូវបានកំណត់ ឬពុំទាន់ត្រូវបានកំណត់ក៏ដោយ។

ង/ ការអនុវត្ត ឬការរារាំងមិនឲ្យអនុវត្តនូវសិទ្ធិ ឬអំណាច ឬកិច្ចអ្វីមួយ។

ច/ ការស្នើជូន ឬការសន្យាថាជូន ទោះបីមានលក្ខខណ្ឌ ឬគ្មានលក្ខខណ្ឌក្តី នូវអត្ថប្រយោជន៍ដូចមានចែងក្នុងស្មារតីនៃកថាខណ្ឌ (ក) (ខ) (គ) (ឃ) និង (ង)។

10. **អំណោយ** មានន័យថា ទ្រព្យ ឬសេវាដែលត្រូវបានផ្តល់ឲ្យទៅបុគ្គលណាម្នាក់ ឬដើម្បីជាប្រយោជន៍ដល់បុគ្គលណាម្នាក់ ហើយដែលមិនត្រូវបានចាត់ទុកជាកិច្ចព្រមព្រៀង និងមិនមែនជាជំនូនតាមទំនៀមទម្លាប់ ឬប្រពៃណី។

11. **ទំនាស់ផលប្រយោជន៍** មានន័យថា ផលប្រយោជន៍ជាទឹកប្រាក់ ផលប្រយោជន៍នយោបាយ ផលប្រយោជន៍ សម្រាប់គ្រួសារ ឬផលប្រយោជន៍ផ្ទាល់ខ្លួន ដែលអាចមានឥទ្ធិពលលើទង្វើរបស់ជនណាម្នាក់ក្នុងការអនុវត្តកាតព្វកិច្ចជាផ្លូវការរបស់ខ្លួន។

12. **ទ្រព្យសម្បត្តិ** មានន័យថា ទ្រព្យគ្រប់ប្រភេទ ទោះជាចលនវត្ថុ ឬជាអចលនវត្ថុ រូបីយ ឬអរូបីយ និងឯកសារគតិយុត្ត ឬលិខិតូបករណ៍ដែលបញ្ជាក់ពីកម្មសិទ្ធិ ឬផលប្រយោជន៍នៅក្នុងទ្រព្យ-សម្បត្តិនោះ។

**13.ផលនៃអំពើពុករលួយ** មានន័យថា ទ្រព្យណាក៏ដោយដែលបានមកពី ឬទទួលបានដោយផ្ទាល់ ឬដោយប្រយោលតាមរយៈការប្រព្រឹត្តអំពើពុករលួយ។

**14.កម្រៃ** មានន័យថា ផលជាប្រាក់បានមកអំពីកិច្ចការការិយាល័យ ឋានៈ មុខងារ ឬការងារដែលរួមទាំងប្រាក់បៀវត្ស ប្រាក់ឈ្នួល និងប្រាក់បន្ថែមឯទៀត។

# ខ- សញ្ញាណនៃអំពើពុករលួយ

( La Notion de la Corruption/ Notion of Corruption )

## ❑ អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ៖

Convention des Nations Unies contre la Corruption (Fr)

United Nations Convention Against Corruption (Eng)

**អំពើពុករលួយ** គឺជាវិបត្តិប្រកបដោយភាពគ្រោះថ្នាក់ ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គមជាតិ។ **អំពើពុករលួយ**ធ្វើឱ្យអន្តរាយដល់លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ នាំទៅដល់ការរំលោភសិទ្ធិមនុស្ស ប៉ះពាល់ដល់ការប្រកួតប្រជែងក្នុងទីផ្សារ បំផ្លាញគុណភាពជីវិត ហើយបានបណ្តាលឱ្យមានឧក្រិដ្ឋកម្មចាត់តាំងជាច្រើន ដូចជាអំពើភេរវកម្ម និងការគំរាមកំហែងដទៃទៀតដល់សន្តិសុខរបស់មនុស្សជាតិឆ្ពោះទៅរករុងរឿងនភាព។

**ស្ថាប័នប្រឆាំងអំពើពុករលួយ**
#54 មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី III ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ (855) 23 219 223
www.acu.gov.kh

**ការទទួលពាក្យបណ្តឹង**
- តាមរយៈប្រៃសណីយ៍ ឬ ប្រអប់សំបុត្រ ស អ.ប.ព.
- តាមរយៈអ៊ីម៉ែល complaint@acu.gov.kh
- តាមរយៈទូរស័ព្ទ ១២៨២ ឬ ០២៣ ២២១ ៦៥៣

**La corruption** est mal insidieux dont les effets sont aussi multiples que délétères. Elle sape la démocratie et l’État de droit, entraîne des violations des droits de l’homme, fausse le jeu des marchés, nuit à la qualité de la vie et crée un terrain propice à la criminalité organisée, au terrorisme et à d’autres phénomènes qui menacent l’humanité.

- **Corruption** is an insidious plague that has a wide range of corrosive effects on societies. It undermines the democracy and the rule of law, leads to violations of human rights, distorts markets, erodes the quality of life and allows organized crime, terrorism, and other threats to human security to flourish.

- ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ៖

**បទល្មើសពុករលួយ** គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុងជំពូកទី៦ (បទល្មើសពុករលួយ និងទោស) នៃច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០។

ឧ- មាត្រា ៥៩៩ (បទស៊ីសំណូក) នៃក្រមព្រហ្មទណ្ឌ

មាត្រា ៦០៥ (បទសូកប៉ាន់) នៃក្រមព្រហ្មទណ្ឌ

មាត្រា ៥៩២ (បទល្មើសវិតិក្រម) នៃក្រមព្រហ្មទណ្ឌ

មាត្រា ៣៥ (បទរំលោភអំណាច)

មាត្រា ៥៨៦ (បទរំលោភអំណាច) នៃក្រមព្រហ្មទណ្ឌ។

# III. ស្ថាប័នប្រឆាំងអំពើពុករលួយ

ស្ថាប័នប្រឆាំងអំពើពុករលួយ មានពីរអង្គ ៖

ក- **ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**

ខ- **អង្គភាពប្រឆាំងអំពើពុករលួយ** ។

ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និង អង្គភាពប្រឆាំងអំពើពុករលួយ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

# ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- **កសាងយុទ្ធសាស្ត្រ** និងនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ពិគ្រោះយោបល់ និងផ្តល់អនុសាសន៍ដល់អង្គភាពប្រឆាំងអំពើពុករលួយពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

❑ **ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ៖**

❖ តែងតាំង ផ្លាស់ប្តូរ និងគ្រប់គ្រង ឬលើកសំណើតែងតាំង ផ្លាស់ប្តូរ មន្ត្រីរាជការក្រោមឱវាទក្នុងអង្គភាពប្រឆាំងអំពើពុករលួយ

❖ ពិនិត្យ និងលើកគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងរបស់អង្គភាពប្រឆាំងអំពើពុករលួយ

# ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- **កសាងយុទ្ធសាស្រ្ត** និងនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ពិគ្រោះយោបល់ និងផ្តល់អនុសាសន៍ដល់អង្គភាពប្រឆាំងអំពើពុករលួយពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

❑ **ការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ៖**

❖ ទទួលនិងពិនិត្យពាក្យប្តឹង ដែលពាក់ព័ន្ធនឹងការមិនអនុវត្តកម្រងព័ត៌មានសេវាសាធារណៈ

❖ បម្រើសេវាការងារជូនក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

# ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

ឃ្លាំមើលដំណើរការការងារនៃអង្គភាពប្រឆាំងអំពើពុករលួយ។

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- **ការងារសហប្រតិបត្តិការអន្តរជាតិ៖**
  - ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការតំបន់ អង្គការអន្តរជាតិនានាដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយឆ្លងដែន

# ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- ស្នើអង្គភាពប្រឆាំងអំពើពុករលួយឱ្យរាយការណ៍ ឬ បំភ្លឺ

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

**❑ ការងារអប់រំបង្ការ ទប់ស្កាត់ និងអនុវត្តច្បាប់**

- ❖ អនុវត្តច្បាប់ បទបញ្ជា និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងបទល្មើសពុករលួយ
- ❖ ដឹកនាំការងារទប់ស្កាត់ និងបង្ក្រាបអំពើពុករលួយ
- ❖ ដឹកនាំការងារឃោសនា អប់រំមហាជនអំពីផលវិបាកនៃអំពើពុករលួយ និងលើកទឹកចិត្តឱ្យមហាជនចូលរួមក្នុងការទប់ស្កាត់ និងកំចាត់អំពើពុករលួយ

# ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

ធ្វើរបាយការណ៍ជូននាយករដ្ឋមន្ត្រីអំពីដំណើរការរបស់អង្គភាពប្រឆាំងអំពើពុករលួយ

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

❑ **ការងារស៊ើបអង្កេត៖**

- តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និងធ្វើការស្រាវជ្រាវ ព្រមទាំងលើកវិធានការនានាពាក់ព័ន្ធនឹងបទល្មើសពុករលួយនៅតាមក្រសួងស្ថាប័ន អង្គភាពសាធារណៈ និងឯកជនទាំងអស់ស្របតាមនីតិវិធីជាធរមាន។
- ទទួល និងពិនិត្យរាល់ពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងអំពើពុករលួយ ព្រមទាំងចាត់ការទៅតាមនីតិវិធីជាធរមាន។
- មានសិទ្ធិធ្វើការព្រមានចំពោះមុខសញ្ញាដែលក្នុងដំណាក់កាលដំបូងមានការខកខានមិនបានអនុវត្តច្បាប់ និងបទប្បញ្ញត្តិជាធរមាន ក្នុងគោលដៅបង្ការនិងទប់ស្កាត់អំពើពុករលួយ។

# ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

ធ្វើរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំជូននាយករដ្ឋមន្ត្រី

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

❑ **ការងារស៊ើបអង្កេត៖**

➢ រក្សាការសម្ងាត់ជាដាច់ខាតចំពោះប្រភពព័ត៌មានទាក់ទងនឹងអំពើពុករលួយ

➢ ចាត់វិធានការចាំបាច់ដើម្បីរក្សាសន្តិសុខដល់បុគ្គលដែលផ្តល់ព័ត៌មានទាក់ទងនឹងអំពើពុករលួយ

# ស្ថាប័នប្រឆាំងអំពើពុករលួយ

## ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

### ភារកិច្ច

រៀបចំនិងអនុម័តបទបញ្ជាផ្ទៃក្នុង ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន។

## អង្គភាពប្រឆាំងអំពើពុករលួយ

### ភារកិច្ច

- **ការរងារកសាងយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ៖** រៀបចំកសាង**ផែនការសកម្មភាព**ប្រយុទ្ធប្រឆាំងអំពើពុករលួយស្របតាមយុទ្ធសាស្ត្រ និងនយោបាយរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

# ស្ថាប័នប្រឆាំងអំពើពុករលួយ

| ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ | អង្គភាពប្រឆាំងអំពើពុករលួយ |
| --- | --- |
| ភារកិច្ច | ភារកិច្ច |

**ភារកិច្ច** (អង្គភាពប្រឆាំងអំពើពុករលួយ)

- ❑ **ការងារគ្រប់គ្រងការប្រកាសទ្រព្យសម្បត្តិ និងបំណុល**
- ធ្វើការគ្រប់គ្រងប្រព័ន្ធប្រកាសទ្រព្យសម្បត្តិ និងបំណុលដូចមានបញ្ញត្តក្នុងច្បាប់នេះ។

**ស្ថាប័នប្រឆាំងអំពើពុករលួយ**
#54 មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី III ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ៖ (855) 23 219 223
www.acu.gov.kh

**ការទទួលពាក្យបណ្ដឹង**
- តាមរយៈប្រៃសណីយ៍ ឬ ប្រអប់សំបុត្រ ស អ.ប.ព.
- តាមរយៈអ៊ីម៉ែល complaint@acu.gov.kh
- តាមរយៈទូរស័ព្ទ ១២៨២ ឬ ០២៣ ២២១ ៦៥៣


ស្ថាប័នប្រឆាំងអំពើពុករលួយ
ក្រុមប្រឹក្សាជាតិ ប្រឆាំងអំពើពុករលួយ
អង្គភាពប្រឆាំងអំពើពុករលួយ
ប្រធាន
អនុប្រធាន
សមាជិក
ប្រធាន
អនុប្រធាន
ក្រុមជនបង្គោល ប្រឆាំង អំពើពុករលួយ
ផ្នែកស៊ើប អង្កេតផ្ទៃក្នុង
អគ្គនាយកដ្ឋានរដ្ឋបាល និងសន្តិសុខ
អគ្គនាយកដ្ឋានប្រតិបត្តិការ
នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
នាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាល
នាយកដ្ឋានសន្តិសុខ
នាយកដ្ឋានប្រកាសទ្រព្យសម្បត្តិ និងបំណុល
នាយកដ្ឋានកិច្ចការគតិយុត្ត ពាក្យប្តឹង និងអន្តរជាតិ
នាយកដ្ឋានអប់រំ បង្ការ និងទប់ស្កាត់
នាយកដ្ឋានបច្ចេកទេស និងកោសលវិច័យ
នាយកដ្ឋានស៊ើបអង្កេត និងចារកម្ម
ការិយាល័យប្រឆាំងអំពើពុករលួយរាជធានី-ខេត្ត

# IV.បទល្មើសពុករលួយ

## បទល្មើសព្រហ្មទណ្ឌទូទៅ ត្រូវកំណត់ដោយធាតុផ្សំចំនួន៣

1. ធាតុនីត្យានុកូល ឬ ធាតុច្បាប់ (ជាបទល្មើសដែលច្បាប់បានចែង)
2. ធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ (ព្យសនកម្មកើតចេញពីអំពើប្រព្រឹត្តល្មើស)
3. ធាតុអត្តនោម័ត ឬ ធាតុចេតនានៃការប្រព្រឹត្ត (ឆន្ទៈ)

យ៉ាងណាមិញ **បទល្មើសពុករលួយ** ក៏ត្រូវបានកំណត់ដោយយោងទៅតាមធាតុផ្សំចំនួន៣ដូចគ្នា៖

ឧទាហរណ៍បទល្មើសពុករលួយមួយចំនួនត្រូវបានកំណត់តាមធាតុផ្សំដូចខាងក្រោម៖

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម និងទោស |
|---|---|---|---|
| ១-បទស៊ីសំណូកនៃនិយោជិត ម.២៧៨ ក្រ.ព្រ.ទ | -និយោជិត | - មានការទទូចសុំ ឬយល់ព្រមទទួលអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ ដើម្បីបំពេញ ឬមិនបំពេញកិច្ចណាមួយនៃមុខងាររបស់ខ្លួនដោយនិយោជកមិនបានដឹង និងដោយគ្មានការព្រមព្រៀង | - ពន្ធនាគារ ៦ខែ ទៅ២ឆ្នាំ<br>- ពិន័យពី ១លានរៀលទៅ ៤លានរៀល |
| ២-បទសូកប៉ាន់ដល់និយោជិត ម.២៧៩ ក្រ.ព្រ.ទ | - គ្រប់បុគ្គល | -មានការប្រគល់...ឲ្យនិយោជិត ដោយនិយោជកមិនបានដឹង និង គ្មានការព្រមព្រៀង | |
| ៣-បទស៊ីសំណូករបស់អភិបាលជាអាទិ៍ ម.២៨០ ក្រ.ព្រ.ទ | -អភិបាល ឬបុគ្គលផ្សេងទៀតដូចមានចែងក្នុងមាត្រា៣៩៣ នៃក្រមព្រហ្មទណ្ឌ | -បានទទួលផលប្រយោជន៍ជាទ្រព្យសម្បត្តិ ឬបានទាមទារ ឬបានសន្យាទទួលផលប្រយោជន៍ ដោយបានទទួលការពឹងពាក់ខុសច្បាប់ | -ពន្ធនាគារ ៥ឆ្នាំ ទៅ១០ឆ្នាំ |
| | -គ្រប់បុគ្គល | បានផ្តល់ផលប្រយោជន៍ ឬបានស្នើសុំផ្តល់ ឬសន្យាផ្តល់ ផល-ប្រយោជន៍ | |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម និងទោស |
|---|---|---|---|
| ៤-បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម<br>ម.៥១៧ ក្រ.ព្រ.ទ | -ចៅក្រមអាសនៈ ឬ ចៅក្រមអយ្យការ | -ទទួចសុំ ឬយល់ព្រមដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលទទួលអំណោយ ជំនូនការសន្យា ឬអត្ថប្រយោជន៍ណាមួយ<br>-បំពេញ ឬមិនបំពេញកិច្ចនៅក្នុងមុខងារ | - ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ |
| ៥-បទសូកប៉ាន់ចំពោះចៅក្រម<br>ម.៥១៨ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់ជូនចៅក្រមនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ<br>-បំពេញ ឬមិនបំពេញកិច្ចជាមុខងារ | - ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ៦-បទស៊ីសំណូករបស់សាក្សីដើម្បីធ្វើសក្ខីកម្មក្លែងក្លាយ<br>ម.៥៤៧ ក្រ.ព្រ.ទ | -សាក្សី | -ទទួចសុំ ឬយល់ព្រម ទទួលយកដោយផ្ទាល់ ឬដោយប្រយោលនូវ អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ<br>-មិនធ្វើសាក្សី ឬផ្តល់សក្ខីកម្មភូតកុហក | ពន្ធនាគារពី ៥ឆ្នាំទៅ១០ឆ្នាំ |
| ៧-បទសូកប៉ាន់សាក្សី<br>ម.៥៤៨ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់ឲ្យសាក្សីដោយផ្ទាល់ ឬដោយប្រយោលនូវ អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍<br>-មិនធ្វើសាក្សី ឬផ្តល់សក្ខីកម្មភូតកុហក។ | |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ៨-បទស៊ីសំណូករបស់អ្នកបកប្រែ<br>ម.៥៥៣ ក្រ.ព្រ.ទ | -អ្នកបកប្រែ | -ទទូចសុំ ឬយល់ព្រមទទួល ដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រ-យោជន៍អ្វីមួយ<br>-ក្លែងខ្លឹមសារនៃភាសា ឬ ឯកសារដែលបកប្រែ | ពន្ធនាគារ ៥ឆ្នាំ ទៅ១០ឆ្នាំ |
| ៩-បទសូកប៉ាន់អ្នកបកប្រែ<br>ម.៥៥៤ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់ឲ្យអ្នកបកប្រែដោយផ្ទាល់ ឬដោយប្រយោល នូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍<br>-ក្លែងខ្លឹមសារនៃភាសា ឬ ឯកសារបកប្រែ។ | |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **១០-បទស៊ីសំណូករបស់អ្នកជំនាញ** ម.៥៥៥ ក្រ.ព្រ.ទ | - អ្នកជំនាញ | -ទទួចសុំ ឬយល់ព្រមដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រ-យោល ទទួល អំណោយ ជំនូន ការសន្យា ឬ អត្ថប្រយោជន៍ណាមួយ<br>-ក្លែងនៅក្នុងរបាយការណ៍ ជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍ដោយ ផ្ទាល់មាត់របស់ខ្លួននូវទិន្នន័យ ឬ លទ្ធផលកោសល្យវិច័យ | ពន្ធនាគារ ៥ឆ្នាំ ទៅ ១០ឆ្នាំ |
| **១១-បទសូកប៉ាន់អ្នកជំនាញ** ម.៥៥៦ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់ឲ្យអ្នកជំនាញដោយផ្ទាល់ ឬដោយប្រយោល នូវអំណោយ ជំនូន កាសន្យា<br>-ក្លែងក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរ ឬសេចក្តីថ្លែងការណ៍ ដោយផ្ទាល់មាត់របស់ខ្លួននូវទិន្នន័យ ឬលទ្ធផលកោសល្យវិច័យ | |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ១២-បទស៊ីសំណូក<br>ម.៥៩៤ ក្រ.ព្រ.ទ | -មន្ត្រីរាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈ ដោយការបោះឆ្នោត | -ទទួចសុំ ឬយល់ព្រមដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោល ទទួលអំណោយ ជំនូន ការសន្យា ឬ អត្ថប្រ-យោជន៍ណាមួយ<br>-បំពេញ ឬមិនបំពេញកិច្ច នៃមុខងារ ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន | -ពន្ធនាគារពី ៧ឆ្នាំ ទៅ១៥ឆ្នាំ |
| ១៣-បទសូកប៉ាន់<br>ម.៦០៥ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់អំណោយ ឬជំនូន ធ្វើការសន្យាជាមួយ ឬផ្តល់ អត្ថប្រយោជន៍ អ្វីមួយ<br>-បំពេញ ឬមិនបំពេញកិច្ច នៃមុខងារ ឬកិច្ចដែលសម្រួលដោយមុខងាររបស់ខ្លួន | -ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ១៤-បទស៊ីសំណូកដោយអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត ម.៦៣៧ ក្រ.ព្រ.ទ | -បុគ្គលក្នុងការប្រកបវិជ្ជាជីវៈ | -ទទួចសុំ ឬយល់ព្រមទទួលយកដោយផ្ទាល់ ឬដោយប្រយោលនូវ អំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ<br>-ធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពី ការណភាព ដែលតាមជាក់ស្តែងមិនមែនការពិត | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |
| ១៥-បទសូកប៉ាន់ចំពោះអ្នកមាននីតិសម្បទាដើម្បីធ្វើលិខិតបញ្ជាក់មិនពិត ម.៦៣៨ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់អំណោយ ជំនូន ការសន្យាជាមួយ ឬផ្តល់អត្ថប្រយោជន៍អ្វីមួយ<br>-ធ្វើលិខិតបញ្ជាក់ ឬវិញ្ញបនបត្ររៀបរាប់ពីការណភាព ដែលតាមជាក់ស្តែងមិនមែនជាការពិត | -ពន្ធនាគារពី ១ឆ្នាំ ទៅ៣ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ៦លានរៀល |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ១៦-បទស៊ីសំណូកដោយសមាជិកនៃគណៈវិជ្ជាជីវៈ ខាងវេជ្ជសាស្ត្រ ដើម្បីធ្វើ លិខិតបញ្ជាក់មិនពិត<br>ម.៦៣៩ ក្រ.ព្រ.ទ | -គ្រូពេទ្យ ឬបុគ្គលដែលជាសមាជិកនៃ គណៈវិជ្ជាជីវៈ វេជ្ជសាស្ត្រ | -ទទួលសុំ ឬយល់ព្រមទទួល ដោយផ្ទាល់ ឬដោយប្រយោល នូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍អ្វីមួយ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |
| ១៧-បទសូកប៉ាន់ចំពោះសមាជិកនៃគណៈ វិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់មិនពិត<br>ម.៦៤០ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ប្រគល់អំណោយ ជំនូន ការសន្យាជាមួយ ឬផ្តល់អត្ថប្រ-យោជន៍ អ្វីមួយដល់គ្រូពេទ្យ ឬបុគ្គលដែលជាសមាជិក នៃគណៈវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ ដើម្បីធ្វើលិខិតបញ្ជាក់ ឬវិញ្ញាបនបត្ររៀបរាប់ពីការណ៍ភាពដែល តាមជាក់ស្តែងមិនមែនជាការពិត | -ពន្ធនាគារពី ១ឆ្នាំ ទៅ៣ឆ្នាំ<br>-ពិន័យពី ២លានរៀលទៅ ៦លានរៀល |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **១៨-បទស៊ីសំណូកនៃមន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសា-ធារណៈ**<br>ម. ៣៣ ច្បាប់.ប.ព | -មន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ | -សុំទាមទារ ឬយល់ព្រមទទួលដោយគ្មានសិទ្ធិ ដោយផ្ទាល់ ឬដោយប្រយោលនូវ អំណោយ ជំនូន ការសន្យា ឬអត្ថ-ប្រយោជន៍ណាមួយ | -ពន្ធនាគារពី ៧ឆ្នាំ ទៅ១៥ឆ្នាំ |
| **១៩-បទសូកប៉ាន់ចំពោះមន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ**<br>ម. ៣៤ ច្បាប់.ប.ព | -គ្រប់បុគ្គល | -ប្រគល់អំណោយ ជំនូន ឬធ្វើការសន្យាជាមួយ ឬផ្តល់អត្ថប្រយោជន៍ដល់មន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការ អន្តរជាតិសាធារណៈ | -ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ២០-បទដេញថ្លៃមិនត្រឹមត្រូវ<br>ម.៣៨៧ ក្រ.ព្រ.ទ | -អ្នកចូលរួមដេញថ្លៃ<br>-គ្រប់បុគ្គលដែលពាក់ព័ន្ធ | -កម្ចាត់អ្នកដេញថ្លៃ ឬធ្វើឲ្យខូចការដេញថ្លៃដោយអំណោយ ការសន្យា ការព្រមព្រៀង ឬតាមមធ្យោបាយទុច្ចរិតដទៃទៀត | -ពន្ធនាគារពី ៦ខែ ទៅ២ឆ្នាំ<br>-ពិន័យពី ១លានរៀលទៅ ៤លានរៀល |
| ២១-និយមន័យនៃការសំអាតប្រាក់<br>ម.៤០៤ ក្រ.ព្រ.ទ | -អ្នកមានសកម្មភាពវិជ្ជាជីវៈ<br>-ក្រុមមានការចាត់តាំង<br>-គ្រប់បុគ្គលដែលពាក់ព័ន្ធ | -យុត្តិកម្មកុហក ដើម្បីលាក់បំបាំងអត្ថប្រយោជន៍ផ្ទាល់ ឬប្រយោលនៃបទ ឧក្រិដ្ឋ ឬបទមជ្ឈិម។ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀល រហូតស្មើនឹងតម្លៃមូលនិធិ ឬតម្លៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសំអាតប្រាក់។ |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ២២-និយមន័យនៃវិតិក្រម ម.៥៩២-៥៩៣ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត | -ទាមទារ ឬទទួល ជាសិទ្ធជាពន្ធ ជាអាករ នូវចំនួនប្រាក់ដែលខ្លួនបានដឹងថាមិនត្រូវបង់ ឬដែលលើសពីចំនួនដែលគេត្រូវបង់<br>-យល់ព្រមក្រោមរូបភាពណាមួយ និងដោយមូលហេតុណាមួយក៏ដោយធ្វើការលើកលែង ឬការលោះលាចំពោះការបង់ពន្ធ ឬ អាករដែលខ្លួនដឹងថាខុសច្បាប់។ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| ២៣-និយមន័យនៃជំនួញឥទ្ធិពលអកម្ម ម.៥៩៥-៥៩៦ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត | -ទទូចសុំ ឬយល់ព្រមទទួលដោយគ្មានសិទ្ធិដោយផ្ទាល់ ឬដោយប្រយោលនូវអំណោយ ជំនូន ការសន្យា ឬអត្ថប្រយោជន៍ណាមួយ ដើម្បីទទួលបានពីស្ថាប័នរដ្ឋដោយសារឥទ្ធិពលពិតប្រាកដ ឬដោយសន្មតនូវការងារលទ្ធកម្មសាធារណៈ គ្រឿងសម្គាល់កិត្តិយស ឬសេចក្តីសម្រេចអនុគ្រោះផ្សេងៗ ដទៃទៀត។ | -ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **២៤-បទជំនួញឥទ្ធិពលសកម្ម**<br>ម.៦០៦ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -ដែលអោយដោយខុសច្បាប់នូវអត្ថប្រយោជន៍ដល់អ្នកដទៃ នៅក្នុងឱកាសនៃការធ្វើលទ្ធកម្មសាធារណៈ គ្រឿងសំគាល់កិត្តិយស ឬសេចក្ដីសម្រេចអនុគ្រោះផ្សេងៗ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ |
| **២៥-និយមន័យនៃបក្ខានុគ្រោះ**<br>ម.៥៩៩-៦០០ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត | -ដែលអោយដោយខុសច្បាប់នូវអត្ថប្រយោជន៍ដល់អ្នកដទៃ នៅក្នុងឱកាសនៃការធ្វើលទ្ធកម្មសាធារណៈ | -ពន្ធនាគារពី ៦ខែ ទៅ២ឆ្នាំ<br>-ពិន័យជាប្រាក់ ១លានរៀល ទៅ ៤លានរៀល |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **២៦-និយមន័យនៃការកេងយកផលប្រយោជន៍ដោយខុសច្បាប់**<br>ម.៥៩៧-៥៩៨ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត | -យកទទួល ឬរក្សាទុក ដោយផ្ទាល់ ឬដោយប្រយោលនូវផលប្រយោជន៍នៅក្នុងសហគ្រាសណាមួយដែល អ្នករាជការ ឬពលរដ្ឋនោះរ៉ាប់រង.. | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |
| **២៧-បទបំផ្លាញដោយចេតនា និងគៃបំបាត់ដោយទុច្ចរិត**<br>ម.៦០១ ក្រ.ព្រ.ទ | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត | -គ្រប់គ្រងលិខិត បណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងទៀត ដោយសារមុខងារ បំផ្លាញចោលដោយចេតនា | -ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ ប្រសិនបើមានចេតនា |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **២៨-បទសម្លុតគំរាម** ម.៦០៧ ក្រ.ព្រ.ទ | -ជនណាមួយ | -ប្រើអំពើសម្លុតគំរាមដែលអនុវត្តទៅលើអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ឲ្យបំពេញកិច្ច ឬមិនឲ្យបំពេញកិច្ចរបស់ខ្លួន | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |
| **២៩-បទបំផ្លាញ និងគែបំបាត់** ម.៦០៨ ក្រ.ព្រ.ទ | -គ្រប់បុគ្គល | -អំពើបំផ្លាញ គែបំបាត់ ឬដកយកលិខិត បណ្ណ មូលនិធិសាធារណៈ មូលនិធិឯកជន ឬវត្ថុអ្វីផ្សេងទៀត ដែលរក្សាទុកដោយអ្នករាជការសាធារណៈ ឬពលរដ្ឋទទួលណត្តិសាធារណៈ ដោយការបោះឆ្នោត | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **៣០-បទរំលោភអំណាច**<br>ម. ៣៥ ច្បាប់.ប.ព | -អ្នករាជការសាធារណៈ ឬពលរដ្ឋទទួលអាណត្តិសា-ធារណៈដោយការបោះឆ្នោត | -ចាត់វិធានការរារាំងការអនុវត្តច្បាប់ដើម្បីទទួលបានដោយខុសច្បាប់ នូវអត្ថប្រ-យោជន៍ណាមួយក្នុងការបំពេញមុខងារ ឬឱកាស នៃការបំពេញមុខងារ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យពី ៤លានរៀល ទៅ ១០លានរៀល<br>- ប្រសិនបើបទល្មើសមានប្រសិទ្ធភាព ទោសពន្ធនាគារដែលត្រូវប្រកាសគឺពី ៥ឆ្នាំ ទៅ១០ឆ្នាំ។ |
| **៣១-បទមានទ្រព្យសម្បត្តិដោយខុសច្បាប់**<br>ម. ៣៦ ច្បាប់.ប.ព | -ជនណាដែលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល<br>(មាត្រា ១៧,១៩ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ) | -ជាកំណើនទ្រព្យសម្បត្តិដែលមិនអាចផ្តល់ការពន្យល់សមហេតុផលនូវការកើនឡើងនៃទ្រព្យសម្បត្តិនេះ ដោយប្រៀបធៀបទៅនឹងចំណូលស្របច្បាប់របស់ខ្លួន | -អាស្រ័យតាមប្រភេទនៃបទល្មើស។ |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **៣២-បទទទួលផលបន្តពីបទល្មើសពុករលួយ**<br>ម. ៣៧ ច្បាប់.ប.ព | -គ្រប់បុគ្គល | -លាក់បំបាំង រក្សាទុក ឬជញ្ជូនរបស់អ្វីមួយដោយដឹងថារបស់នោះបានមកពីបទល្មើសពុករលួយ | -ពន្ធនាគារពី ២ឆ្នាំ ទៅ៥ឆ្នាំ<br>-ពិន័យពី ៤លានរៀលទៅ ១០លានរៀល<br>(ក្នុងករណីមានស្ថានទម្ងន់ទោស ពន្ធនាគារ ពី ៥ ឆ្នាំទៅ ១០ឆ្នាំ) |
| **៣៣-បទមិនប្រកាសទ្រព្យសម្បត្តិ និងបំណុល**<br>ម. ៣៨ ច្បាប់.ប.ព | -ជនណាដែលមានចែងនៅក្នុង មាត្រា១៧ មាត្រា ១៨ និងមាត្រា១៩ នៃច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ | -មិនបានប្រកាសទ្រព្យសម្បត្តិ និងបំណុល ឬ<br>-ប្រកាសមិនត្រឹមត្រូវនូវទ្រព្យសម្បត្តិរបស់ខ្លួន។ | -ពន្ធនាគារពី១ខែ ទៅ១ឆ្នាំ និងពិន័យពី ១សែនរៀល ទៅ ២លានរៀល។<br>- ក្នុងករណីរឹងរូស មិនព្រមប្រកាសទ្រព្យសម្បត្តិ ទោសដែលត្រូវប្រកាសគឺទ្វេដង។ |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
|---|---|---|---|
| **៣៤-បទទម្លាយការសម្ងាត់នៃប្រភពព័ត៌មានស្តីពីអំពើពុករលួយ**<br>ម. ៣៩ ច្បាប់.ប.ព | -ជនណាមួយ | -ធ្លាយការសម្ងាត់នៃប្រភពព័ត៌មានស្តីពីអំពើពុករលួយ | -ពន្ធនាគារពី ១ឆ្នាំ ទៅ៥ឆ្នាំ |
| **៣៥-បទរារាំង និងជ្រៀតជ្រែកដល់ការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ**<br>ម. ៤០ ច្បាប់.ប.ព | -អ្នករាជការសាធារណៈ យោធិន នគរបាលជាតិ ពលរដ្ឋ ដែលទទួលអាណត្តិតាមការបោះឆ្នោត មន្ត្រីសង្គមស៊ីវិល មន្ត្រីសាធារណៈបរទេស ឬមន្ត្រីនៃអង្គការអន្តរជាតិសាធារណៈ | -សម្លុតគំរាមកំហែង រារាំង ឬជ្រៀតជ្រែកក្នុងការបំពេញមុខងាររបស់មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ | -ពន្ធនាគារពី២ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យពី ៤លានរៀល ទៅ ១០លានរៀល។ |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
| --- | --- | --- | --- |
| ៣៦-បទបរិហារ ដោយភូតកុហក<br>ម. ៤១ ច្បាប់.ប.ព | -គ្រប់បុគ្គល | -ប្តឹងបរិហារដោយភូតកុហក ដល់អង្គភាពប្រឆាំងអំពើពុករលួយ ឬតុលាការនូវអង្គហេតុបទល្មើសពុករលួយ ដែលនាំទៅដល់ការស្រាវជ្រាវឥតប្រយោជន៍ | -ពន្ធនាគារពី ១ខែ ទៅ៦ខែ<br>-ពិន័យជាប្រាក់ពី ១សែនរៀល ទៅ១លានរៀល |
| ៣៧-បទបំពានលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក<br>ម. ៤២ ច្បាប់.ប.ព | -គ្រប់បុគ្គលទាំងឡាយណាដែលគ្មានសិទ្ធិ | -ផ្ទេរ ធ្វើអនុប្បទាន ឬធ្វើការដោះដូរនូវទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការចាប់យក ។ | -ពន្ធនាគារពី១ឆ្នាំ ទៅ៥ឆ្នាំ និងពិន័យពី ២លានរៀល ទៅ ១០លានរៀល។ |

| ឈ្មោះបទល្មើស | ប្រធាននៃបទល្មើស | ធាតុសត្យានុម័ត | ទណ្ឌកម្ម ឬទោស |
| --- | --- | --- | --- |
| ៣៨-បទល្មើសពុករលួយតូចតាច និងទោស ម. ៤៣ ច្បាប់.ប.ព | -ជនណាមួយ | -ប្រព្រឹត្តឡើងសម្រាប់ជីវភាពប្រចាំថ្ងៃ ដែលមានលក្ខណៈតូចតាច មិនបង្កព្យសនកម្មធ្ងន់ធ្ងរ ដល់សង្គម<br>-មានការវាយតម្លៃទទួលស្គាល់ពី អង្គភាពប្រឆាំងអំពើពុករលួយ ថាជាបទល្មើសតូចតាច | -ពន្ធនាគារពី ៧ថ្ងៃ ទៅ៥ឆ្នាំ |

## V- សំណួរ-ចម្លើយ

# សូមអរគុណ !